# English for Study in Australia
# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## LESSON 16 – Around campus
## មេរៀនទី១៦៖ នៅជុំវិញសាខាសាកលវិទ្យាល័យ

**STUDY NOTES**
**ឯកសារជំនួយមេរៀន**

តួអង្គ

Rocky:
រ៉ុកឃី ៖ និស្សិតអន្តរជាតិ។
John:
ចន ៖ និស្សិតអន្តរជាតិនៅសាកលវិទ្យាល័យ។
Student:
និស្សិត ៖ បុរសដែលគេមិនធ្លាប់ស្គាល់។

សាច់រឿង
រ៉ុកឃីទៅលេងចននៅសាកលវិទ្យាល័យ។

**ព័ត៌មាន – អគារនិងសេវាសិក្សានៅសាកលវិទ្យាល័យ**
ខាងក្រោមនេះគឺជាបញ្ជីនៃប្រភេទអគារនិងសេវាមួយចំនួន ដែលលោកអ្នកឧស្សាហ៍ជួបប្រទះ នៅតាមសាខានៃសាកលវិទ្យាល័យ។

| | |
|---|---|
| Student Administration Building៖ អគាររដ្ឋបាលនិស្សិត | ការិយាល័យកណ្តាលសម្រាប់ផ្តល់ព័ត៌មានដល់និស្សិត។ ជាទីកន្លែងដែលនិស្សិតអាចទៅបង់ប្រាក់ ចុះឈ្មោះចូលរៀន ឬចុះឈ្មោះចូលរៀនឡើងវិញ ឬដាក់ពាក្យសុំឯកសារ ឬសុំសញ្ញាបត្រ។ |
| Student Union Building អគារសហជីពនិស្សិត | ជាញឹកញាប់ជាកន្លែងដែលនិស្សិតជួបជុំគ្នា។ ជាធម្មតាទីនេះ មានកន្លែងសម្រាប់ប្រជុំក្លិប កន្លែងញុំាអាហារ កន្លែងលេងកីឡាជាដើម។ |


© RadioAustralia/AMES 2008

| | |
|---|---|
| Caf/Cafeteria/food hall<br>កន្លែងលក់ភេសជ្ជៈ/<br>កន្លែងលក់អាហារ/អាហារដ្ឋាន | ជាកន្លែងលក់ចំណីអាហារ។ ជាធម្មតា កន្លែងនេះមានទីតាំងនៅក្នុងអគារសហជីពនិស្សិត និងជួនកាលជាអាហារដ្ឋានដោយមានជំនួយឧបត្ថម្ភ។ ដូច្នេះ អាហារក្នុងកន្លែងនេះ ច្រើនមានតម្លៃថោកជាងអាហារទិញពីខាងក្រៅសាខាបរិវេណសាកលវិទ្យាល័យ។ |
| Medical centre<br>មណ្ឌលសុខភាព | ជាទីកន្លែងដែលលោកអ្នកអាចពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិត, អ្នកពិគ្រោះយោបល់ និងពេទ្យមានជំនាញឯកទេសផ្សេងៗទៀត ព្រមទាំងពេទ្យធ្មេញជាដើម។ ប្រសិនបើសាកលវិទ្យាល័យ មិនមានមជ្ឈមណ្ឌលសុខភាពទេ ជាធម្មតា អគារសុខភាពអាចមានទីតាំងជាប់ទៅនឹងអគារវេជ្ជសាស្ត្រធំមួយដែលស្ថិតនៅជិតសាខាសាកលវិទ្យាល័យនោះ។ |
| Theatre<br>រោងមហោស្រព | សាកលវិទ្យាល័យភាគច្រើន យ៉ាងតិចណាស់មានរោងមហោស្រពដ៏ធំមួយ ដើម្បីឱ្យនិស្សិតសម្តែងពីស្នាដៃផ្សេងៗ និងសម្រាប់បើកសម័យបង្រៀនពេញអង្គ។ |
| Library<br>បណ្ណាល័យ | សាខាសាកលវិទ្យាល័យ យ៉ាងតិចណាស់ក៏មានបណ្ណាល័យមួយដែរ។ អគារសហជីពរបស់និស្សិតមួយចំនួន មានបណ្ណាល័យសិក្សា ដែលមិនសង្កត់ធ្ងន់លើការសិក្សាទាំងស្រុងឡើយ ហើយនៅទីនេះ លោកអ្នកអាចខ្ចី DVDs តន្ត្រី និងសៀវភៅដែលមានការពេញនិយម។ |
| Gym<br>កន្លែងហាត់ប្រាណ | កន្លែងហាត់ប្រាណរបស់និស្សិត សម្រាប់ការធ្វើលំហាត់ប្រាណ ដែលជាធម្មតាមានតម្លៃថោកជាងតម្លៃក្នុងមជ្ឈមណ្ឌលកីឡា នៅក្រៅសាខាសាកលវិទ្យាល័យ។ |
| Sports facilities<br>ទីកន្លែងសេវាកីឡា | សាកលវិទ្យាល័យមួយចំនួន មានតារាងបាល់បោះ និងតិនីស។ |
| International Students´ | ជាដេប៉ាតឺម៉ង់ ដែលបង្កើតឡើងសម្រាប់បំពេញតម្រូវ |


© RadioAustralia/AMES 2008

| | |
|---|---|
| building អគារនិស្សិតអន្តរជាតិ | ការរបស់និស្សិតអន្តរជាតិ។ |

**ភាសា-សំនួនវោហារ និងឃ្លាប្រយោគដែលមានន័យមិនធម្មតា**

| | |
|---|---|
| "Sorry, I didn't catch that" | សូមទោស ខ្ញុំមិនយល់ទេ។ តើអ្នកអាចនិយាយម្តងទៀតបានទេ? |

## EXERCISES
## លំហាត់

### ១. វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| amazing | award | beer |
| botany | chess | compulsory |
| directions | hamburger | impressive |
| intersection | locker | Magician |
| photography | (to) starve | union |

### ២. ការហាត់រៀនភាសា លំហាត់គំរូ ការធ្វើតេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវធ្វើតេស្តដើម្បីស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។


© RadioAustralia/AMES 2008

Choose the word that best completes each sentence.

ចូរជ្រើសពាក្យដែលសមស្របបំផុតសម្រាប់ដាក់ទៅក្នុងចន្លោះនៃអត្ថបទក្នុងប្រអប់ខាងក្រោម។

សូមគូសខ្វែងក្នុងប្រអប់មួយស្រាប់ពាក្យនីមួយៗ។ ឧទាហរណ៍ ☒

1. Could you tell me ___________ the business faculty is please?

☐ why ☐ which ☐ where ☐ stand

2. How can I ___________ the Magicians' Club?

☐ join ☐ joining ☐ join up ☐ joins

3. Joining the student union is not ________________. It's optional.

☐ compulsive ☐ compulsory ☐ compelling ☐ compel

4. Just turn right at the next building then go ________________ ahead to the corner.

☐ up ☐ around ☐ straight ☐ along

5. It's __________ the left, opposite the student union building.

☐ at ☐ over ☐ by ☐ on

## ៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា

ស្វរសំឡេង / ɜ: / and /ɔ:/ ៖ សូមហាត់និយាយ**ពាក្យដែលត្រូវ**ពត់អណ្តាតរួចបញ្ចេញសំឡេងឲ្យបានឮៗ ៖

"The girl walks to work on Thursday morning."

## ៤. អាសយដ្ឋានអ៊ីនធើរណិតដែលមានប្រយោជន៍


© RadioAustralia/AMES 2008
ABC Radio Australia

| | |
|---|---|
| ព័ត៌មាន ៖<br>សាកលវិទ្យាល័យគំរូ ៖<br>ផែនទី និងអគារ ៖ | http://www.pb.unimelb.edu.au/CampusMaps/Parkville.pdf |
| ឧទាហរណ៍ក្លិបនៅ<br>សាកលវិទ្យាល័យ | http://www.union.unimelb.edu.au/?clubs/ |

ចម្លើយលំហាត់ទី 2: 1) where 2) join 3) compulsory 4) straight 5) on

ABC Radio Australia


© RadioAustralia/AMES 2008